## Asking and saying whether something is correct




### កិច្ចការសាលា

ប្អូនស្រី៖ បង! បងជួយមើលលំហាត់នេះខ្ញុំធ្វើត្រូវអត់?
បងស្រី៖ ម៉េចក៏ពីរបូកពីរស្មើប្រាំវិញ? ខុសហើយ។ ឥឡូវអូនឯងសាកលើកម្រាមដៃពីរឡើងមើល ហើយថែមម្រាមពីរទៀត។ រាប់មើល ទៅជាម៉ាន?
ប្អូនស្រី៖ មួយ ពីរ បី បួន។
បងស្រី៖ ហ្នឹងហើយ។ ហើយអូនឯងគិតម៉េចឃើញប្រាំ?
ប្អូនស្រី៖ ខ្ញុំច្រឡំ។

### ការគណនាលេខនៅលើ Excel

ធារី៖ ដាណែត ជួយមើលលេខនេះតិចមើល។ ខ្ញុំបូកត្រូវអត់?
ដាណែត៖ មើល ខ្ញុំមើលតិចមើល។ ហើយធារីម៉េចក៏មិនប្រើរូបមន្តបូកនៅលើ Excel ម៉ងទៅ?
ធារី៖ ខ្ញុំអត់ចេះ។ តែខ្ញុំប្រើកាស្សូបូកតាស មិនមែនបូកដៃឯណា។
ដាណែត៖ ប្រើកាស្សូ ពេលខ្លះយើងចុចច្រឡំអីទៅក៏មាន។ ចាំខ្ញុំបង្រៀនបូកនៅលើ Excel ... ឃើញអត់? បានហើយ។ ត្រូវតាស ធារីឯងបូកអត់ខុសទេ។ លេខតិច យើងប្រើកាស្សូបាន តែបើលេខច្រើន ពិបាកម៉ង។
ធារី៖ ធ្វើតាមដាណែតលឿនជាង។ ប្រើកាស្សូ យឺតហើយអាចខុសទៀត។ អរគុណ ដាណែត។

| | |
|---|---|
| កិច្ចការសាលា | homework |
| លំហាត់ | exercise, homework |
| ម៉េចក៏ ... ? | Why ... ? |
| បូក | + (as a mathematical operation); to add (up) |
| ... វិញ | phrase-final: indicates that something shouldn’t be so |
| ទៅជាម៉ាន? | How much do you get? – ម៉ាន is the spoken form of ប៉ុន្មាន |
| គិតម៉េចឃើញប្រាំ? | How did you calculate it and got 5? |
| ធារី, ដាណែត | female Cambodian names |
| ... តិចមើល | softens or makes a request more polite |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| រូបមន្ត | formula |
| ម៉ង | spoken form of តែម្ដង = directly, right away |
| កាស្យូ | calculator (from the company name Casio) |
| តាស | affirmative particle |
| មិនមែនបូកដៃឯណា | emphatic: I didn’t add it up by hand! |
| ចាំ ... | I will ... |

## Talking about basic mathematical operations

| | |
|---|---|
| 3 + 4 = 7 | បីបូកបួនស្មើនឹងប្រាំពិល |
| 3 – 5 = –2 | បីដកប្រាំស្មើនឹងដកពីរ |
| 5 – 3 = 2 | ប្រាំដកបីស្មើពីរ ឬ ប្រាំដកបីសល់ពីរ |
| 3 x 4 = 12 | បីគុណនឹងបួនស្មើនឹងដប់ពីរ ឬ បីបួនដងស្មើនឹងដប់ពីរ |
| 12 : 2 = 6 | ដប់ពីរចែកនឹងពីរស្មើនឹងប្រាំមួយ |
| $3^2 = 9$ | បីស្វ័យគុណពីរស្មើនឹងប្រាំបួន, specifically for squares: បីលើកជាការេ |
| ¾ (as a fraction) | បីភាគបួន ឬ បីលើបួន |
| 0.75 | សូន្យចុចចិតប្រាំ ឬ សូន្យក្បៀសចិតប្រាំ |

## Additional dialogue

ដាណែត៖ ធារី ជួយមើលឃ្លាអង់គ្លេសនេះតិចមើល។ ខ្ញុំបកខ្មែរអីចឹង ត្រូវអេ៎?
តិចខុសន័យគេចង់និយាយ។

ធារី៖ ដូចមិនមែនអីចឹងទេដឹង ដាណែត។ គេចង់និយាយថា ... ព្រោះអី
នៅមុខនេះគេនិយាយអំពី ...។

ដាណែត៖ អីចឹងអ៎? មើល ខ្ញុំគិតមើលតិចសិន។ មែនហ្នឹងអ៎ា ប្រហែលដូចធារីឯងនិយាយហើយ។

ធារី៖ សាកសួរបងកុសលតិចទៅ ដើម្បីឲ្យច្បាស់។

ដាណែត៖ អូខេ អីចឹង ខ្ញុំយកទៅសួរគាត់តិចសិន។ អរគុណ ធារី។

| | |
|---|---|
| បកខ្មែរ | to translate into Khmer |
| អេ៎ | spoken form of the question or negation particle ទេ |
| តិច ... | phrase-initial: maybe ... |
| ដូចមិនមែនអីចឹងទេដឹង | this doesn’t seem to be right |
| អីចឹងអ៎? | Really? |
| មែនហ្នឹងអ៎ា | You’re right... |
| កុសល | male Cambodian name |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.